ព្រះរាជាណាចក្រ កម្ពុជា

មន្ទីរស្ដីការ ក្រសួងសិក្សាធិការ

# ទស្សនាវដ្ដី

សម្រាប់

គ្រូបង្រៀន

ឆ្នាំទី ១ លេខ ៩

ខែមិថុនា - កក្កដា ព.ស. ២៤៩៣

ឆ្នាំសិក្សា ១៩៤៩ - ១៩៥០

ព្រះរាជាណាចក្រកម្ពុជា

មន្ទីរស្ដីការ ក្រសួងសិក្សាធិការ

# ទស្សនាវដ្ដី

# សម្រាប់ គ្រូបង្រៀន

## បញ្ជីរឿង

ទំព័រ


វេយ្យាករណ៍ ........................................ ១
ឧត្ដមដ្ឋាន ........................................ ៣
មជ្ឈិមដ្ឋានទី ២ ........................................ ៦
— — ទី ១ ........................................ ៧
អាទិកដ្ឋាន ........................................ ១០
មេសូត្ររត់មាត់ ........................................ ១៨
មជ្ឈិមដ្ឋានទី ១ នព្វន្ត ........................................ ២៣
រង្វាស់រង្វាល់ ........................................ ២៦
ធរណីមាណសាស្រ ........................................ ២៩
បរិវច្ឆណដ្ឋាន នព្វន្ត ........................................ ៣២
កុមារដ្ឋាន នព្វន្ត ........................................ ៣៤

# វេយ្យាករណ៍

ខែនេះនៅទីបុងឆ្នាំ ការបង្រៀនភាសាខ្មែរគប្បីសើរើរៀនឡើងវិញមេរៀនដែលបានរៀនរួចហើយ នឹងឲ្យរៀននិបាតសព្ទបញ្ចប់ ។ វិធីប្រើអាយតនិបាតជាការសំខាន់ក្នុងភាសាខ្មែរ សុំលោកគ្រូទាំងឡាយបង្វឹឲ្យសិស្សមើលឡើងវិញរឿយៗ (ទស្សនាវដ្ដីខែមេ១៩៤៨ ទំព័រពី ៣៦ ទៅ ៣៨)

ឧត្តមដ្ឋាន

# ខ្ញុំទៅកំសាន្តចិត្តឯកែប

នៅពេលចូលឆ្នាំខ្មែរបីថ្ងៃ ឪពុកខ្ញុំបាននាំខ្ញុំទៅលេងរកខ្យល់អាកាសឯកែប ។

ម៉ោង៦ព្រឹក លុះរៀបចំសំពត់អាវដាក់ក្នុងវ៉ាលិសនិងម្ហូបអាហារ សំរាប់ទទួលទានតាមផ្លូវស្រេចហើយ ខ្ញុំឪពុកនិងម្តាយខ្ញុំក៏ចេញដំណើរទៅ ដោយឡានឈ្នួលតូចមួយ ។ នៅតាមផ្លូវខ្ញុំបានឃើញភូមិនិងស្រុកគេ ដ៏មានផ្ទះតូចៗពីគ្នា ផ្ទះអស់ទាំងនោះច្រើនសង់នៅជុំគ្នា ។ នៅពីភ្នំពេញប្រហែលជាសែសិបគីឡូម៉ែត្រ ខ្ញុំឃើញនៅខាងស្តាំដៃខ្ញុំ ភ្នំមួយមានព្រះវិហារនៅលើកំពូល ដែលគេហៅថាភ្នំស្រពៅ ហើយនៅឆ្ងាយដាច់កន្ទុយភ្នំក៏ឃើញផ្លូវភ្នំកំពត ។ ដល់ចម្ងាយប្រហែលមួយរយគីឡូម៉ែត្រ ខ្ញុំទៅដល់ផ្សារកំពត ។ នៅសងខាងផ្លូវមានភ្នំៗដែលនៅខាងស្តាំដៃ មិនសូវមានច្រើនទេ ហើយមានដុះដើមឈើជិតៗគ្នា ខ្ពស់ៗមានវល្លិ៍ព័ទ្ធ ៗ នៅខាងឆ្វេងដៃ ខ្ញុំឃើញភ្នំមួយទៀត មានសុទ្ធតែថ្ម មានក្រហែងក្រហូន ព្រោះបាក់ង្យបាន ខ្យល់បក់បំបែកថ្មនោះមកក្រោមផ្លូវថ្នល់ ។ លុះម៉ោងប្រាំបួន ខ្ញុំទៅដល់ផ្សារកំពត ខ្ញុំនិងឪពុកខ្ញុំក៏ឈប់នៅផ្សារនោះបន្តិច ដើម្បីនិងមើលទីផ្សារ ហើយនិងទិញអីវ៉ាន់យកទៅទទួលទានផង ។ ផ្សារនោះសប្បាយណាស់មានទំនិញស្ទើរតែគ្រប់មុខ ខ្ញុំឃើញមានការពិយ៉ាន់ឈ្មួញ ដែលគ្រាន់តែធុំក្លិនទឹក

ឃ្លានបាយ ៗ មានទឹកត្រីក្រអូប មានហាប់ងៀតត្រីបម្រុង គឺងៀតត្រីផ្ទុន
សមុទ្រ ងៀតបំពែល ងៀតត្លាមហើយនិងងៀតឯទៀតជាច្រើន ដែលខ្ញុំ
មិនស្គាល់ឈ្មោះ ៗ មានលក់បន្លែនិងលក់ផ្លែឈើផ្សេងៗពីទីក្រុងភ្នំពេញ ៗ
នៅខាងក្រៅផ្សារ មានលក់មាក់ប្រាង សារម៉ាវ សេមាន ម្នាស់កំពតជ
មានខុជាសៅម្ពួរ មានផ្លែគុយ ផ្លែព្រូននិងផ្លែឈើច្រើនទៀត
ដែលទើបបានមកពីភ្នំ ៗ ក្ដិផ្សារត្រូវមួយដែលសង់នៅមាត់ដៃសមុទ្រ មាន
លក់ត្រី លក់ង៉ាវ លក់កំពឹស ក្ដាមសេះ សាកយ ហើយនិងមានលក់ផ្អក
ង៉ាវ យូហឺ បង្កៀ ត្រីឆ្អើត្រីអណ្ដែងទន់ ៗ លុះទិញអីវ៉ាន់បានស្រេចហើយ
ខ្ញុំនិងពុកខ្ញុំក៏ចេញដំណើរទៅកែបទៀត ៗ តាមផ្លូវខ្ញុំឃើញមានសួនតែ
ចំការម្រេចដែលមានដនូនជួបជាមួ លុះដិតទៅដល់កែប ខ្ញុំគិតសាកយ
ខ្យល់បក់នាំយកមកពីសមុទ្រ មិនយូរប៉ុន្មាន ខ្ញុំឃើញសមុទ្រកែបធំឥតឃើញ
ត្រើយ ជមានកាពជួបជាក់កលមួយសស្អាត ៗ លុះទៅដល់កន្លែងដែលគេ
ធ្វើសំពៅទុកឲ្យអ្នកទឹក ឃើញផាំងផ្សព្វាក់ឈរចាំនៅមុខនោះ យកម្ហូបនិងបាយ
មកនាំគ្នាទទួលទានលើស្មៅ នៅជើងភ្នំជិតមាត់សមុទ្រ ព្រោះថ្ងៃជិតត្រង់ហើយ ៗ
ឃើញទឹកសមុទ្រខ្ញុំនឹកសប្បាយហើយចង់តែចុះទៅងូតលេង ប៉ុន្តែខ្ញុំមិនហ៊ាន
ព្រោះខ្លាចប៉ិតពុកខ្ញុំ ខ្ញុំនឹកតែសប្បាយពុំទេះដាប់ ៗ ទទួលទានរួចស្រេច
ហើយយើងទៅឈរលេងនៅផ្ទះតូចមួយ ដើម្បីនឹងឲ្យជាតិអាហាររកស្រួល
និងចាំឲ្យមេឃស្រទំបន្តិច ៗ ខ្ញុំឃើញរលកធំៗជាតិមកប៉ះនឹងច្រាំងជមានសូរ

គ្រាំងៗ មានមនុស្សជាច្រើនងូតទឹកកក្រោកលោតហែលលេងសប្បាយ ៗ ឃើញគេលេងផ្លោះ ខ្ញុំគិតតែចង់ងូតណាស់ទៀត ៗ ប្រហែលកន្លះម៉ោងតមក ខ្ញុំក៏ចុះងូតទឹក មុនដំបូងខ្ញុំមិនហ៊ានទៅឆ្ងាយពីច្រាំងទេ ខ្លាចលង់ហើយខ្លាចសមុទ្រជង ៗ លុះខ្ញុំឃើញគេទៅច្រើននាក់ ខ្ញុំក៏លុះចិត្តទៅជាមួយនឹងឪពុកខ្ញុំៗទៅចុះទីជម្រៅដែលមានចុះសាភាយ ខ្ញុំមិនដឹងក៏ទៅអណ្តែតលេងលើប្លង់នោះ លុះលកភ្លាយមកទឹកសាបចូលមាត់ខ្ញុំ ដឹមានជាតិប្រៃដូចជាទឹកដែលឃើងលាយអំបិល ៗ ខ្ញុំក៏ក្រោកឡើងឈរ ដើម្បីឲ្យផុតលេក ៗ ឃើងដកសាភាយបានច្រើនក៏ត្រឡប់មកខាងវិញ ខ្ញុំអណ្តែតលេងលើដីខ្សាច់ រើសសំបកខ្យងល្អៗមកគរទុកដើម្បីយកមកផ្ទះ ៗ ងូតទឹកសមុទ្ររួចហើយ យើងមកលាងខ្លួននឹងទឹកសាបនៅក្នុងបន្ទប់តូច ហើយយើងនាំគ្នាទៅមើលផ្កាកែប ៗ យើងផ្លូវកន្ទប់១ នឹងសំណាក់ លុះព្រឹកឡើងកាលណាយើងក៏ត្រឡប់មកវិញតាមផ្លូវកំពត យើងឈ្វាតចូលទៅមើលកន្លែងមួយដែលហៅថាទឹកឈូរ បម្លាយប្រហែលជា១០គីឡូមេត្រ ៗ ទីនោះមានច្រោះជ្រៅប្រហែល៨មេត្រ ដមានបាតសង់ថ្មដាំដំៗមានទឹកថ្លាដូចកញ្ចក់ មានដុំថ្មធំសង់ពន្លូលដូចត្រាប់តាំកើង បំពាំងនោះសិកនឹងទឹកហូរ ៗ យើងមើលទីនោះរួចហើយក៏ត្រឡប់មកកំពតរហូតដល់ភ្នំពេញ យើងទិកតែសប្បាយមិនគួរ កាលណាមានឱកាសនឹងទៅលេងម្ដងទៀត ៗ

មជ្ឈមណ្ឌលទី ២

## ដើមស្វាយទិព្យឬស្វាយកល្ប

មហាក្សត្រិយ៍មួយព្រះអង្គ បានមកពីព្រៃហិមពាន្ត ផ្លែស្វាយទិព្យដែលមានឫទ្ធិអាចធ្វើមនុស្សចាស់ត្រឡប់ជាក្មេងបាន ។ ទ្រង់មិនប្រាថ្នានឹងសោយតែមួយព្រះអង្គឯង ទើបស្ដេចត្រាស់ឲ្យយកទៅបណ្ដុះដាំ ដើម្បីបានផ្លែច្រើននឹងប្រទាន ចែកដល់រាស្ត្រនុរាស្ត្រផង ។ ស្វាយនោះដុះលូតលាស់ល្អ ។ លុះដល់មានផ្លែ នៅក្រោមគល់ស្វាយមានរូងអាសិរពិសជាប្រក្រតី ។ ពិសពស់ក៏ជ្រួតជ្រាបសព្វសពាង្គនៃឈើ ។ មានផ្លែមួយនោះព្រះរាជាទ្រង់ឲ្យនាយទ្វារបានបេះផ្លែស្វាយមកថ្វាយដើម្បីនឹងសោយ ។ ពួកពិសេសក៏បិតស្វាយដាក់ភាជនៈស្រេចហើយលើកទៅថ្វាយ ។ មនុស្សដែលតែងភ្លក្សព្រះក្រយាស្ងោយក៏យកចំណិតតូចមួយមកភ្លក្សចំពោះព្រះភក្ត្រ ។ ជាតិស្វាយនោះបំពុលអ្នកភ្លក្សស្លាប់ភ្លាម ។ ទ្រង់ទតព្រះនេត្រឃើញហេតុដូច្នោះហើយ ទ្រង់ក៏សរសើរព្រេងសំណាងរបស់ព្រះអង្គក៏បោះបង់ស្វាយពុលចោលទៅ ជាស្វាយដែលគេស្ទើរខ្ទបកល់គ្នា ។ ក្រោយមកអាសិរពិសលែងនៅក្នុងរូងក្រោមគល់ស្វាយទៅ ។ ស្វាយតែងបង្កើតផលដូចធម្មតា ។ លុះយូរលង់មកពលរដ្ឋប្ដីប្រពន្ធសិនចាស់ៗជរាយទៀយណាស់ប្រាស់នឹងជាតិកំណើតស់ទៅ ក៏បេះផ្លែស្វាយមួយមកបរិភោគតាំងពីទោកដើម្បីឲ្យក្ស័យជីវិតទៅ ប៉ុន្តែតាចាស់ផ្លាស់រូបទៅជាក្មេងកំលោះសាច់ឈាមឡើងស្រស់បំព្រង សក់ខ្មៅរលើបរលង់ យាយ

ពស់ផ្លាស់រាងកាយជាក្រមុំដ៏មានខ្លួនសក្តិសម ដោះទៀនក្បូងខ្ទិនទុក យាយទិនតាមើលគ្នាពុំស្គាល់យល់តែសំដី សរីរៈទាំងឡាយក្លាយជាយរ័ទ្ធិស្វាយទិព្យ កិត្តិសព្ទរន្ទឺរន្ទ្រដល់ព្រះទិព្វស្រោត ទើបស្តេចឲ្យបេះផ្លែស្វាយមកថ្វាយ ទ្រង់ឲ្យភ្លក្សមើលដូចប្រវេណី អ្នកភ្លក្សក៏ប្រែក្លាយរូបដូចពលដំរីប្តីប្រពន្ធនោះឯង ។ ព្រះរាជាក៏សោយជាមួយ និងព្រះរាជវង្សានុវង្ស ព្រះកាយាទៀងជាយុវតីយុវា ទើបព្រះរាជាទ្រង់ឲ្យពិនិត្យមើល ក៏ឃើញហេតុថា ស្វាយនោះទៅជាពុល ព្រោះមានអសីពិស ។

---

ពាក្យពន្យល់ .- ទិព្វ ឬ ទិព្យ=របស់សួគ៌ របស់វិសេស ។ - អាសីពិស ឬ អាសិរពិស ឬ អាសីវិស = សត្វមានពិសក្នុងចង្កូម គឺពស់ ។ - ភ្លក្ស = ស៊ីបន្តិចមើលរសជាតិជាដំបូង ។ - សរិរៈ ឬ សរិល=រាងកាយ ។ ព្រះទិព្វស្រោត=ត្រចៀកស្តេច(រាជស័ព្ទ) ។

ពាក្យសួរ .- រឿងនេះមានអាថ៌ដូចម្តេច? (អំពីសេតគប់)

មជ្ឈិមដ្ឋាន ទី ១

## ព្យុះសង្ឃរានៅឆ្នាំរោងឆស័កពុល្ល, ១២៦៦ (1904)

នៅក្នុងខែពិសាខ ក្រោយវេលាដែលព្រះបាទស៊ីសុវត្ថិ បានទទួលរាជសម្បត្តិដំណរពីព្រះបាទនរោត្តម ក្នុងកំឡុង ៤ ឬ ៦ ថ្ងៃ មានខ្យល់ព្យុះធំនៅក្រុងភ្នំពេញនិងក្នុងខេត្ត បណ្តាដែលនៅជុំវិញ ។ ខ្យល់ធំព្រមទាំងភ្លៀងរកាំមធំ តាំងពីថ្ងៃរសៀលរហូតអស់មួយយប់ត្រឹមនឹងមួយព្រឹក ។

កាលដើមឡើយ គេឃើញពពកខ្មៅពាសពេញ ដូចជាមេឃជូនទោទន់ ហាក់ចង់ទំនន់ពុំបាន ។ មួយស្របក់មក ខ្យល់ធ្លាក់រំភើយ ព្រមទាំងរលឹម ។ ខ្យល់បក់ខ្លាំងឡើងបន្តិច ៗ ជួនមកពីឯលិច ជួនពីឯត្បូង ជួនពីឯជើង ខ្យល់កាន់តែខ្លាំងឡើង ៗ សត្វសន្ធឹកគ្រគ្រាក់ ដូចជាគេចំលាក់បុរំលំក្ខ ឈើព្រឹក្សលតាវល្លិ៍ញាប់ញ័ររើរក់ ផ្ទះអ្នកស្រុករបើកដំបូល របើងដំបូល ទឹកភ្លៀងហូល ដូចនៅកណ្ដាលវាល ទីវាលដូចជាគោកចាលទ្រុល មនុស្សម្នាមហាជន ពួនសំងំរួចដែកក្រោមបាន សត្វពាហនរត់ផ្ដាក់ផ្អើលបញ្ចេញពីក្រោលឃ្នង ៗ ព្យុះស្ងប់ទៀបថ្ងៃត្រង់ នោះគេដើរតាមគន់ចំណាំសត្វសាវតារ គេឃើញដើមឈើកដ៍ពីដើម ឈើធំ ៗ រលំរលើង ខ្លះមានឫសចះឡើងស៊ើរតែស្មើនឹងកំពស់ដើមវិញ ។ ដើមត្នោតដេកជាចង្ហាលព្រៃតឹងព្រៃនឹងគ្នា ។ ចំការបេក ចំការអំពៅបាក់កប់ដូចគេផ្ដេកគ្នាសំលៀមដើមឡើយ ។ ផ្លែស្វាយការធ្លាក់ពេញនៅក្រោមដើម ។ ប៉ុន្តែខ្យល់ព្យុះនេះជាព្យុះអស្ចារ្យ គេហៅជ្រូនទាំងប៉ុន្មានសង់នៅជាំ ទាំងទូកនាវាធំតូចក៏ពុំមានអន្តរាយមួយសោះឡើយ ឯ-មហាជនទាំងឡាយណានៅក្នុងក្រុងព្យុះ ក៏ពុំមានជួបប្រទះស្លាប់បង់ជីវិត ឬពិ-ការដោយសារព្យុះនោះឡើយ ។

ពន្យល់ពាក្យ.— ព្យុះ, ពាយុ, វាយុ, វាយោ, វេរ៉ា= ខ្យល់; ខ្យល់បក់ខ្លាំងគឺ ព្យុះ ។ ខ្យល់រត់ក្នុងខ្លួននៃយើង ឬក្នុងអាកាសហៅវាត, វាតគុល្ម ឬចក្រវាត= ខ្យល់កំបុតត្បូង ។ ឈើរាជ ឈើចាស់តាំងពីបុរាណមក ។

# ពលីការសុំទឹកភ្លៀង

កាលពីដើមខ្ញុំបានឃើញបណ្ដាជនស្រុកស្រែ រៀបពលីសុំទឹកភ្លៀង នៅឆ្នាំណាទឹកភ្លៀងក្រ ៗ បណ្ដាជនអ្នកដើរវត្តទៅប្រជុំគ្នាក្នុងទីអាកាស រៀបពិធីបីថ្ងៃ ។ ក្នុងរបៀបពលីនោះគេជីករណ្ដៅចតុរស្រមួយ ទំហំពីរហត្ថ មួយចំអាម ជំរៅមួយហត្ថ ធ្វើកជវត្តព័ទ្ធជុំវិញ ទុកទ្វារបួនឈមទៅទិសទាំងបួន មានឆត្រក្រមួយ ៗ នៅមុំ និងឆត្រមួយតូច ស្លាធម៌មួយតូចត្រង់ទ្វារទាំងបួន និងស្លាធម៌ទិសបួនទៀត ។ គេសូនរូបត្រីរស់មួយដាក់ក្នុងរណ្ដៅ ឈមមុខទៅឦសាន សូនរូបទេវតាមួយអង្គឈរក្នុងស្រះឬរណ្ដៅនោះ ព្រះភក្ត្រងើយទៅលើ ឈមមុខទៅឦសាន ព្រះហស្តឆ្វេងស្ទួយព្រះអង្គ ព្រះហស្តស្ដាំលាតចង្អុលទៅលើឈមឦសាន ។ គេចាក់ទឹកទៅក្នុងរណ្ដៅ ពន្លិសីមាជុំវិញព្រះភជវត ហើយចាក់ភ្ជាប់អំបោះសីមានោះ ទៅព្រះដ៏ក្នុងព្រះវិហារ ។ ដំបូងគេនិមន្តព្រះសង្ឃសូត្រព្រះបរិត្តវេលាល្ងាច វេលាថ្ងៃត្រង់ទើបឧបាសកឧបាសិកា នូវតាយកទាយិកា សម្បូរសម្រែងព្រមគ្នាបំពោះទៅទេវតាពលាហក សុំឲ្យបណ្ដាលទឹកភ្លៀងធ្លាក់មក រួចហើយទើបនិមន្តលោកសង្ឃបួនអង្គ ឈរជុំវិញរណ្ដៅឈមមុខទៅក្នុងស្រះនោះ រួចសូត្រធម៌ដែលមានអាទិ៍ថា ៖

សព្ពោទ្ធា បមហាបេក ..... ត្រាតែបាន ១០៨ ចប់ ទើបអស់ពិធីនាថ្ងៃដំបូង ។ ពិធីបុណ្យនេះជាគំរប់ ៣ ថ្ងៃ ។

កាលក្នុងរជ្ជព្រះបាទស៊ីសុវត្ថិ មានឆ្នាំមួយនោះក្រទឹកភ្លៀងណាស់ សត្វពាហនដូចជាគោក្របី សេះជ្រូកមាន់ទា ស្លាប់វិនាសជាច្រើន ដោយអត់ទឹក ។ គោខ្ទះស្លាប់ទៅមានសុទ្ធតែកក្កុងគ្រោះ ឯមនុស្សម្នាមហាជនក៏គាស្រ័យនៅក្នុងស្រុកភូមិដោយលំបាកវេទនាពេកពន់ ព្រោះអត់បាយខ្វះអត់ទឹក ទើបគេរៀបពិធីសុំទឹកភ្លៀងគ្រប់ភូមិស្រុក ភ្លៀងក៏មានឡើងបានធ្វើការកេស៊ីជាសុខសប្បាយ ជំងឺដំកាត់ផ្សេងៗ ក៏អន្តរធានបាត់ទៅ ។

ពន្យល់ពាក្យ.— ពលី ឬ ពលិ = ការបូជា ។ ភជវតិ = របង ; វត្ថុបទុមវតីគឺវត្ថុមានល្បូកជារបង; វដ្ដី = វិលទៅមក ; ទស្សនាវដ្ដី = ការឃើញទៅមុកវិញ ។— ពលាហក = ទេវតាដែលបង្អុរភ្លៀង ។ — អង្គៃ = បង្គៈ ។ — ព្រះដីរ៍ = ព្រះបដិមានៃព្រះរូបព្រះពុទ្ធ ។

អាធិកដ្ឋាន

## បង្រៀនពាក្យនិងភាសា

### អាទិត្យទី ១– អំពីពេលវេលា

នាម– ថ្ងៃ យប់ អាទិត្យ ខែ ឆ្នាំ មួយរំពេច មួយស្របក់ ម៉ោង នាទី (មិនុត) ។

គុណនាម– ភ្លឺ ងងិត យូរ ឆាប់ ឆ្នាំចាស់ ឆ្នាំថ្មី ខែមុន ខែក្រោយ ដើមខែ ចុងខែ កណ្ដាលខែ ។

កិរិយាសព្ទ — ខាតពេលវេលា កត់ថ្ងៃ ខែ ឆ្នាំ មើលម៉ោង ថ្ងៃរះ ថ្ងៃលិច ថ្ងៃតាំង ។

ហាត់ភាសា — ដែលគេហៅថាពេលវេលានោះគឺអ្វី? ក្នុង ១ ឆ្នាំ មានប៉ុន្មានខែ? គឺខែអ្វីខ្លះ? ខ្មែរយើងរាប់ឆ្នាំជាប៉ុន្មាន? គឺឆ្នាំអ្វីខ្លះ? ក្នុងមួយអាទិត្យមានប៉ុន្មានថ្ងៃ? គឺថ្ងៃអ្វីខ្លះ? ក្នុងមួយខែមានប៉ុន្មានថ្ងៃ? ក្នុង ១ ថ្ងៃ ១ យប់មានប៉ុន្មានម៉ោង?

## បង្រៀនមើល

### អំពីពេលតាមរបៀបខ្មែរ

(សៀវភៅគ្រូស្វាធ្យាយន៍បរិវេណផ្លូនទំព័រ ១០៨)

កែជម្រើ — អាស្វុជ = អស្សុជ ។ បឋមសាធ = បឋមាសាឍ

## សរសេរតាមសូត្រ

### អំពីពេលវេលា

ដែលហៅថាពេលវេលានោះគឺ គេសម្រេចយកតាមកំណត់ដំណើរព្រះធរណីវិលជុំវិញខ្លួនឯង ហើយនិងវិលក្រវ៉ង់ជុំវិញព្រះអាទិត្យផង ។ ពេលដែលព្រះធរណីវិលបានមួយជុំខ្លួនឯងនោះ ហៅថាមួយថ្ងៃមួយយប់ គឺម្ភៃបួនម៉ោង លុះព្រះធរណីវិលបានមួយជុំព្រះអាទិត្យ ទើបហៅថាមួយឆ្នាំ មួយឆ្នាំមានបីរយហុកសិបប្រាំថ្ងៃ ឬ ហាសិបពីរអាទិត្យ ។

ដែលហៅថាផ្គរនោះ គឺគគ្រឹកគំហ៊ុនដែលខ្យល់អាកាសផាត់ស្ទួរគ្នាគគ្រឹក មួយផ្ទាំៗ ។

សរសេរពាក្យពីបាក.— ដំណើរ ព្រះធរណី ព្រះអាទិត្យ ម្ភៃ ហុកសិបប្រាំ ហាសិបពីរ ខ្យល់ ផ្លាស់ប្ដូរ ។

## តែងសេចក្ដី

ចូលអ្នកអធិប្បាយអំពីអ្នកប្រើពេលវេលាដូចម្ដេចខ្លះ តាំងពីព្រលឹមឡើង ហូតដល់ព្រលប់ ។

### ទំនងតែង

តាំងពីព្រលឹមហូតដល់ពេលបាយ អ្នកធ្វើអ្វីខ្លះ? ចុះពេលបាយទល់នឹងព្រលប់អ្នកធ្វើអ្វីទៀត?

## អក្សរផ្ចង់

បង្រៀនសរសេរអក្សរ “មូល”

## បង្រៀនពាក្យនឹងភាសា

អាទិត្យទី ២.— អំពីខ្យល់

នាម.— ខ្យល់ ខ្យល់រំភើយ ខ្យល់ដំនោរ ខ្យល់ព្យុះ ព្យុះសង្ក្រ ខ្យល់កំបុតត្បូង (ខ្យល់គួច) ខ្យល់ពីងពើង ។

គុណនាម.— រហើយ ត្រសៀក ត្រជាក់ រងា តិច ខ្លាំង រក់រី ៗ

កិរិយាសព្ទ.— ខ្យល់បក់តិចៗ ខ្យល់បក់ខ្លាំង ខ្យល់ផ្លុចផ្លូល បហើរ ខ្ទេន បើកក្តោង ៗ

ក. ហាត់ភាសានិងការហាត់សរសេរ សុំគ្រូតែងធ្វើជូនសព្វជន ៗ

## បង្រៀនមើល

### អំពីខ្យល់បក់មកពីទិសខាងជើង

សៀវភៅវិជ្ជាខេមរភាសាបរិបូណ៌ជាន់ ទំព័រ ៦៤ មេរៀនទី ៤៣

## សរសេរតាមសូត្រ

### អំពីខ្យល់

កាលណាយើងឈរ ឬអង្គុយនៅកណ្ដាលទីវាល ហាក់ដូចជាមានអ្វីមកប៉ះពាល់ខ្លួនយើងនាំឲ្យស្រហើយ នេះហៅថាខ្យល់ ៗ ឯស្លឹកឈើដែលកំរើកទៅមកបាន នោះគឺខ្យល់បក់ ៗ ខ្យល់បក់នេះ ជួនខ្លាំង ជួនតិច ខ្យល់បក់តិចៗហៅថាខ្យល់ជំនោរ ខ្យល់បក់ខ្លាំងហៅថាព្យុះ កាលណាខ្យល់នោះបក់ខ្លាំងអស្ចារ្យ ហៅថាព្យុះសង្ឃរា ៗ ខ្យល់ព្យុះអាចធ្វើឲ្យដើមឈើ ផ្ទះសម្បែង ទូក កប៉ាល់ អន្តរាយបាន ៗ

ខ្យល់មានប្រយោជន៍ ដើម្បីឲ្យអ្នកជិះទូក សំពៅបើកក្តោងលឿនទៅបានឆ្ងាយ ៗ

សរសេរពាក្យពិបាក ។— ខ្យល់ ល្ហើយ កល ព្យុះសង្ឃរា អន្តរាយ អស្ចារ្យ កញ្ឆាល់ លឿន ។

## តែងសេចក្ដី

ចូរអ្នកអធិប្បាយអំពីខ្យល់ព្យុះតាមពាក្យចោទខាងក្រោមនេះ ៖

យ៉ាងដូចម្ដេចដែលហៅថាខ្យល់ព្យុះ? នៅក្នុងរដូវណាដែលមានខ្យល់ព្យុះ? ខ្យល់នោះបក់មកពីទិសខាងណា? មុននឹងមានខ្យល់នោះ អ្នកសំគាល់ឃើញហេតុអ្វីនៅលើមេឃ? វេលាខ្យល់នោះបក់មក អ្នកធ្វើដូចម្ដេចខ្លះ? អ្នកឃើញមានអ្វីកើតឡើងផង? អ្នកឃើញខ្យល់នោះបណ្ដាលឲ្យមានហេតុអ្វីខ្លះ នៅក្នុងភូមិអ្នក-នៅក្នុងខេត្ត? អ្នកចូលចិត្តនឹងខ្យល់នោះឬទេ? ពីព្រោះអ្វី? ។

## បង្រៀនពាក្យនឹងភាសា

អាទិត្យទី ៣.— អំពីភ្លៀង — ឥន្ទធនូ

នាម.— ភ្លៀង ផ្គរ រន្ទះ ផ្លេកបន្ទោរ ឥន្ទធនូ សន្សើម ត្រាប់ ភ្លៀង ទឹកភ្លៀង ។

គុណនាម.— ច្រើន តិច ស្រិចៗ ប្រោយៗ ស្រិម ទទឹកជោក សើម ។

កិរិយាសព្ទ.— រាំងភ្លៀង ភ្លៀងស្រក់តក់ៗ ទឹកភ្លៀងជក់ ទឹកភ្លៀងជ្រាបនៅក្នុងដី ត្រង់ទឹកភ្លៀង ងូតទឹកភ្លៀង ។

ការហាត់ការហាទនឹងការហាត់សរសេរ សុំគ្រូតែងធ្វើដូចសព្វដង

# អំពីនាឡិកា

នាម.— នាឡិកាយោល នាឡិការោទ៍ នាឡិកាដាក់ ផ្ទះនាឡិកា គ្រឿងនាឡិកា ខ្សែឡាន កូនសោ ប៉ោល ទ្រនិច លេខ កញ្ចក់ ថៃ

គុណនាម.— ទៀង យឺត លឿន តាំង ខូច ដាច់ឡាន ថ្មី ចាស់ ។

កិរិយាសព្ទ.— មួលនាឡិកា ផ្ទៀងនាឡិកាឬម៉ោង បង្វិលទ្រនិច មើលម៉ោង នាឡិកាដើរ នាឡិកាឈប់ (គេថានាឡិកាស្លាប់) ។

១ ទៀតត្រូវបង្រៀនពាក្យដែលកើតអំពីឫសគល់ដូចគ្នា ពាក្យប្រើផ្ទុយគ្នា និងពាក្យផ្ទួន ។

## សរសេរតាមសូត្រ

# អំពីភ្លៀង

ទឹកភ្លៀងបង្កើតមកអំពីពពក ឯពពកកើតឡើងអំពីចំហាយទឹកនៅវេលាដែលត្រូវកំដៅព្រះអាទិត្យ ប្រមូលផ្ដុំគ្នាឡើងហើយអណ្ដែតទៅលើអាកាស កាលណាពពកនោះសោតទៅប្រទះនឹងខ្យល់ត្រជាក់ខ្លាំងក៏កកទៅជាទឹក ហើយធ្លាក់មកជាទឹកភ្លៀង ទឹកភ្លៀងជ្រាបទៅក្នុងដីសព្វបញ្ចេញមកក្រៅ ជាតិទាំងឡាយ ឬផ្ដុំគ្នាកើតបានជាដើមទឹក មួយចំណែកទៀតហូរធ្លាក់ទៅក្នុងស្ទឹងត្រពាំង បឹង ស្រះ ទន្លេ សមុទ្រ ។ កាលណាមានភ្លៀងច្រើន មានព្យុះ ផ្គរ ផ្លេកបន្ទោរ ហើយនឹងរន្ទះផង ។

ពាក្យពិបាក.— ផ្គុំ អណ្ដែត រលោក រុក្ខជាតិ ព្យុះ ផ្គរ ផ្លេកបន្ទោរ ។ ភ្លៀងសររសោបាុនពីយ៉ាង ភ្លៀងឬផ្លៀង ។

## តែងសេចក្ដី

១— ចូរអធិប្បាយអំពីភ្លៀងតាមពាក្យចោទខាងក្រោមនេះ ៖ នៅស្រុកខ្មែរយើង រដូវណាដែលមានភ្លៀងច្រើន? ភ្លៀងនោះធ្លាក់មកពីណា? វេលាមុនភ្លៀងអ្នកឃើញមានអ្វី ហើយអ្នកឮសូរអ្វី នៅលើមេឃ? នៅវេលានោះ មេឃយ៉ាងដូចម្ដេច? លុះបន្តិចមកទៀតអ្នកឃើញមានអ្វីស្រក់ចុះមក ហើយហូរធ្លាក់ទៅឯណា? នៅក្នុងស្រែឬក្នុងថ្លុកត្រពាំងអ្នកឃើញមានអ្វី? នៅក្នុងរដូវនោះអ្នកស្រែចំការធ្វើអ្វីខ្លះ? ឯទឹកទន្លេឡើងឬស្រក? អ្នកចូលចិត្តទឹកភ្លៀងឬទេ? ពីព្រោះអ្វី?

២— ចូរអ្នកអធិប្បាយអំពីនាឡិកាដក់ តាមពាក្យចោទខាងក្រោមនេះ ៖ អ្នកមាននាឡិកាដក់ឬទេ? នាឡិកានោះធ្វើអំពីអ្វី? ពណ៌វាយ៉ាងដូចម្ដេច? នៅខាងមុខវាអ្នកឃើញមានអ្វីខ្លះ? ឯក្រវិលទង់កំពូលវាសំរាប់ធ្វើអ្វី? ឯទ្រនិចវាទាំងពីរប៉ុនគ្នាឬទេ ហើយវិលស្មើគ្នាឬទេ? ទ្រនិចមួយបង្គុលអ្វី? ទ្រនិចមួយទៀតបង្គុលអ្វី? បើអ្នកយកនាឡិកាដក់មកដាក់ជិតត្រចៀកអ្នកឮសូរដូចម្ដេច? អ្នកស្រឡាញ់នាឡិកាអ្នកឬទេ? ពីព្រោះអ្វី?

# ១– តែងសេចក្ដីជាគំរូ

ចូរអ្នកអធិប្បាយអំពីថ្ងៃមួយដែលមានភ្លៀងមួយមេយ៉ាងធំ ។ អ្នកបានឃើញដូចម្ដេចខ្លះ នៅវេលាមុនភ្លៀង វេលាកំពុងភ្លៀង វេលាក្រោយភ្លៀង? យោបល់យល់ឃើញរបស់អ្នក? ។

## សេចក្ដីអធិប្បាយជាគំរូ

កាលពីថ្ងៃ ២៣ ខែឧសភា គ. ស. ១៩៥០ នៅក្រុងភ្នំពេញមានភ្លៀងមួយមេយ៉ាងធំ មុននឹងភ្លៀងនោះ ខ្ញុំឃើញមេឃងងឹតស្លុកបន្តោរព្រាតៗ ផ្គរលាន់រំពងទិស បានបន្តិចមានខ្យល់បក់មកយ៉ាងខ្លាំង ហើយមានដំណក់ទឹកធ្លាក់មកជាមួយផង ។

ឯស្លឹកឈើដោយត្រូវនឹងទឹកភ្លៀងធ្លាក់មកជាប់នោះ ក៏ទន់ទោរសំយ៉ុងចុះមកក្រោម តែវេលាណាខ្យល់បក់មក ដំណក់ទឹកនោះហូរស្រក់តក់ៗដូចជាធារនៃទឹកក្នុងមុខគួរឲ្យស្ងើចណាស់ ។ ឯដីទំនាបលិចអស់ឃើញសុទ្ធតែទឹក នៅលើផ្លូវទាំងអស់លើកតែថ្នល់ដែលចាក់កៅស៊ូចេញ ក៏បែកកក់ស្អិតដូចជាបាយម៉ានដែលអាចធ្វើឲ្យជាប់បាតស្បែកជើង អ្នកដើរជើងទាំងប៉ុន្មានដើរបានតែលបៗ ហើយឱនក្បាលកោងខ្នងបន្តិចផង ព្រោះប្រុងប្រយ័ត្នកុំឲ្យរអិល ឬស្អិតជាប់ជើងបាន ។ រីឯរថទឹមសេះ ក្របក្រយ៉ាន រថយន្ត សុទ្ធតែបើកឬលើកដំបូល ក៏ប៉ុន្តែវេលាណាខ្យល់បក់មកខ្លាំងទឹកភ្លៀងក៏បាចសាចចូលទៅពេញ

ផ្លែផល ៗ ក្នុងពេលនោះមិនសប្បាយទេ ព្រោះមនុស្សសត្វជាប់នៅតែក្នុងផ្ទះ ឬក្នុងម្លប់ ចេញទៅណាមកណាមិនរួចអារម្មណ៍តែងតែទទឹកទនិងទឹកភ្លៀង ៗ ពេលនោះជាពេលនាំឲ្យលំបាកចិត្តណាស់ ៗ ដោយកំពូលប្រហែលជាម៉ោងប្រាំកន្លះ នៅលើមេឃឃើញមានពន្លឺព្រះអាទិត្យលេចបន្តិច ៗ ឡើង ឯពពកក៏កាន់តែភ្លឺបន្តិចម្តង ៗ ទៅ គឺដឹងថាពេលល្អជួបធម្មតានោះត្រឡប់មកវិញហើយ មនុស្សនិងសត្វទាំងឡាយក៏បានសេចក្តីរីករាយ ដូចពេលធម្មតាឡើងវិញដែរ ៗ

ខ្ញុំបានយល់ឃើញថា ទឹកភ្លៀងមានប្រយោជន៍ដល់មនុស្សសត្វជាទីបំផុត ប៉ុន្តែបើភ្លៀងច្រើនហួសប្រមាណនឹងនាំឲ្យវិនាស ឬខូចខាតផលប្រយោជន៍ទៅវិញក៏សឹងមានដែរ ៗ ៚

## មេស្សុត្រតំមាត់

ទន្លេមេគង្គ

ទន្លេមេគង្គនេះគឺជា ជលធារធំដល់ទី ហូរចាក់ធ្លាក់ចុះមកអំពី គីរីស្រុកចិនឈ្មោះទីបេ ៗ វែងជាងបួនពាន់គីឡូម៉ែត្រ កាត់ខេត្តនិគមពុំឈប់ទេ បណ្តោយទៅភ្ជាប់ទន្លេ គឺមេទឹកមួយកាត់ស្រុកយើង ៗ ប្រមូលស្ទឹងអូរឯទៀតព្រោះ ព្រំដែនជ្រោយបន្ទោះជ្រោះទៅលើង ក្នុងពួកតាតាមទំនើង រលើងធ្លាក់ចុះដល់ទីល្បាក ៗ ពេលទឹកជំនន់ទន្លេនោះ ជន់ចែកតពុះច្រុះធ្លាយធ្លាក់

ហូរនាំល្បប់ដីយកមកដាក់ តពោក់ឡើងកើតកោះសម្បត្តិ ។ ហើយបណ្ដាលផុះ ពសុធា កលាស្រុកទេសប្រទេសស្អាត ទាបខ្ពង់ជាហូរច្រាយច្រាត់ សោតទៅ ធ្លាក់ក្នុងសមុទ្រ ។

---

ពន្យល់ពាក្យ.— ជលធារា — "ម. បឹ. ជ:ល:ធារា" ន. ខ្សែទឹក, ធ្លារទឹក ។

ល្បាក់ — ន. ថ្នាក់ដែលធាក់របេះ ឬដែលមានសណ្ឋានដូចជាបាក់ : ល្បាក់ច្រាំងទន្លេ ។

ពសុធា — ន. ផែនដី; ពីភពលោក "ប. ត"

## រឿងមើលកំសាន្ត

### ឆ្មាំនិងកណ្ដុរចាស់ (តពីវេឧសភា)

ពេលនោះកណ្ដុរ ចាស់មួយត្រសុល ត្រឡប់ចូលមកផត ឃើញពួកខ្ទង់វ៉ាប់ កប់រោយដោយប្អូន ចៃបតាមិត្ត ស្គាល់ពិតជាគ្នា ។ "ទើបពោលថា អើ! អាឯងក្រោនចើ ចេះប្រើប្រាជ្ញា បន្ទំធ្វើមេ្យ៉ង ផងរឹងបៅគ្នា អញស្គាល់វិកអា អស់ហើយកុំលាក់ ។ កាលអញកម្លោះ មិនឯងលោតផ្លោះ មកក្លាយត្រជាក់ កន្ទុយអញដាច់ សាច់ឈាមស្រោក អញនៅចាំជាក់ ចាប់លាក់ម្នុខថ្មី ? ។ បើទុកជាដុំ ម្សៅនោះហ៊ានធំ ប៉ុនក្ដុំផងក្ដី ទាំងឈ្មួយវាំងទាញ ក៏អញមិនខ្វី សុំទេចំណី នេះស្បែងខ្លាំងណាស់ ។ មិនបោកកូនក្មេង ទំពាស៊ីលេង ហ៊ានហ៊ឺរហ័ប ពីព្រោះក្មេងព្រៀប ទើបវាយការណស់ ហ៊ានអញក្បាលចាស់ បោកក្រុសមេ្តចវាយ ?» ។

គួរសរសើរណាស់ ពាក្យគណ្ហាចាស់ នេះបេះនិយាយ បេះការសត្រូវ មិនស្ងួតពាយផ្កាយ ចិត្តឥតកយមាយ បេះទាយទោសខ្លួន ។ ស្គាល់ផ្លូវ កុំឆ្កាប់ ស្គាល់ផ្លូវរស់ស្លាប់ ស្គាល់ផ្លូវកន្សែង ស្គាល់ផ្លូវបញ្ញាគ ស្គាល់ផ្លូវ ក្រមិច មិនផ្ដែលក្តាំងក្តួច របរិលតែកង ។ រូបដកពិត តែត្រង់តំនិត រំង វិតតែកង ពោះក្នុងដំទង់ ក៏តង់មិនជាង គួរកុំរំលាង ពាក្យចាស់ហោលអើយ ។

(ប.គ.)

---

## រាត្រីខែភ្លឺ

ក្រោយពេលសុរិយង្គអស្តង្គត លិចផុតចំនួនមួយម៉ោងទៅ
ព្រះច័ន្ទ្រចាំងចែងសែងសន្ធៅ នៅលើចុងព្រឹក្សព្រៃទាំងឡាយ ។
ភិតផាត់សោត់គន្ធុំ វនកុសុមក្រអូបសាយ
ពេលក្លិនមកមុនរំភើយផ្ងាយ ក្លាយជន្តើមហិមវ័ង្សី ។
អឌ្ឍរាត្រីកាល ភ្លឺប្រាលបំប្លងក្នុងរាត្រី
លេចឡើងសន្សឹមសៀងវិមទ្វី បញ្ចាំងរស្មីពេញផ្ទៃមេឃ ។
ផ្លូវណាៈស្ងួចយាងតាមមាគ៌ា ក្នុងផ្ទៃនភាភ្លឺអនេក
ផ្លូវណាផ្ការកក្នុងស្រទាប់មេឃ ពពកជៀតជែ ពាសបំពាំង ។
សភាពដូចភ្នំធំពន្លឺក មានទឹកកកជាប់នៅទាំងផ្លាំង
ប្រិតប្រេកិតខ្ចប់បិទបាំង បីដូចរនាំងបាំងលំអ ។

---

ពន្យល់ពាក្យ.— សុរិយង្គ — ន. "ព្រះអាទិត្យ"

អស្តង្គត — កិ. ឬ គុ. ព្រះអាទិត្យលិច

គន្ធ — (ម. ឋ. គន៌ធ) ន. ក្លិន

ធុំ — កិ. ធុំក្រអូប

ប្រថាប់ – កិ. ឈប់, ឈរ, អង្គុយ

វនកុសុម – (ម. ថ. វន: កុសុម) ន. ផ្កាព្រៃ ។

ហិមរង្សី – (ម. ថ. ហិម: រង្សី) ន. ព្រះច័ន្ទ ។

អគ្គនារី – ន. ឬ គុ. ស្ត្រីខ្ពស់បំផុត ស្តេចស្រី ។

រត្តិកាល – ន. ពេលយប់

នភា – (ម. ប. នៈភ) ន. ពពក, មេឃ

(ប. ត.)

# រាត្រីខែភ្លឺ (ត)

វិការដ្ឋានលើភូមិភព    ប្រារភឲ្យឃើញផែនដីល្អ
ណាស់ដែរសូម្បីតែល្អាងថ្ម    កំឃើញព្រះច័ន្ទនិទ្រារម្មណ៍ ។
ប្រថាប់សម្រាកកាយសម្រាន្ត    នៅក្នុងស្មសានហើយកំផ្ទុំ
ផកកំរើកអង្គផ្ទង់អារម្មណ៍    សំងំក្នុងគុម្ពតិណជាតិ ។
រុក្ខច្ឆាយាធ្មុះចេញស្មោះ    មើដូចភាពកោះស្មុងៗព្រាត
អណ្តែតត្រសែតទៅតាមភាគ    ហាក់ជាតុឱយៈផ្ញើករស្មី ។
គ្រើពសូរស្លឹកឈើធ្លាក់មក    និងសូរខ្យល់បោកក្នុងរាត្រី
នៅមានសម្លេងសត្វបក្សី    ហួងរាត្រីបរយំម្តងៗ ។
ក្នុងមជ្ឈិមយាមយប់ស្ងប់ស្ងាត់    ត្រជាក់ពេកក្តត់គតសៅក្មេង
ជាទីរីករាយក្រៃកន្លង    ទាំងផែនភពផងសិងសប្បាយ ។

ពន្យល់ពាក្យ.–

វិការដ្ឋាន – ន. កន្លែងដែលមានហេតុកើត ។

ប្រារភ – កិ. តាំងផ្តើម, ផ្តួចផ្តើម ។

ល្អាង – ន. រណ្តៅងឬថ្មកថ្ម កើតឯងនៅភ្នំ ។

និទ្រារម្មណ៍ – ន. ដំណើរដេកលក់ ។

អារម្មណ៍ — ន. ការដឹង,...

តិណជាតិ — ន. ស្មៅ

រុក្ខជាយា — ន. ស្រមោលម្លប់ឈើ ។

វាត — ន. ខ្យល់ ។

ជាតុឧយៈ — ន. ជាតុទឹកសមុទ្រ ។

រាត្រីចរ — គុ. ឬនាម; មៀម, ទុយ,

ខ្លែងស្រាក ។ល។ (ប. គ.)

## គ្រូពេទ្យនឹងលាញី

លោកគ្រូពេទ្យម្នាក់ជិះលាញី ដើម្បីទៅទីមនុស្សជម្ងឺ

មួយដែលកំពុងតែដេកឈឺ តឹកកើតពិសរោគខាន់ស្លាក់ ។

ពេលពេទ្យដល់ផ្ទះជម្ងឺនោះ ក៏ចុះពីលាទៅរាក់ទាក់

និងមនុស្សស្គាល់គ្នាជាមិត្តភក្តិ នៅទ្វារផ្ទះ អ្នកដែលកើតរោគ ។

មេលាគ្រឿងគ្រប់សម្រាប់ជិះ ដែលជាជំនិះរបស់លោក

ចូលតាមទ្វារផ្ទះដើរទៅឈ្លោក មើលអ្នកមានរោគកំពុងដេក ។

អ្នកឈឺឮស្សូរជើងមកជិត គិតស្មានថាៈពេទ្យនឹកអពោក

ហុចដៃឲ្យគ្រូគមិនក្រឡេក ងាកភ្នែកមើលក្រោយដោយទុកចិត្ត ។

លាញីឃើញដៃមកចំមុខ យកមាត់ជញ្ជក់ពាំទាំស្អិត

អ្នកឈឺងាកមកឃើញលាលិទ្ធ ភ័យភិតចុះពីគ្រែដំណេក ។

ពន្យល់ពាក្យ.— ខាន់ស្លាក់.— ន. ឈ្មោះរោគមួយយ៉ាងកើតកណ្តាលក ធ្វើឲ្យលេបបាយ-ទឹកពុំរួច ។

រាក់ទាក់—កិ.វិ. ឬ គុ. ដែលពោលស្រុះស្រួល ទទួលដោយអើពើ, ចៅភើ ។

មិត្តភក្តិ—ន. សេចក្តីស្មោះត្រង់ចំពោះមិត្ត ។

# គ្រូពេទ្យនិងលាញី (ត)

ទើបឃើញលាចេញដោយទោមនស្ស ហើយអស់សំណើចសើចខ្ទាំងពេក
ពិសក្នុងបំពង់កនោះបែក អ្នកឈឺនឹកត្រេកអរផុតបី ។
ពេទ្យចូលមកទាល់គិតនឹងភាត់ លានឹងរំពាត់វែងខ្សែតី
តែអ្នកជម្ងឺឃាត់ហាមខ្ទី ថា : « សូមប្រណីកុំវាយវា ។
គួរឲ្យអស្ចារ្យណាស់លោក ចេះមកមើលរោគខ្ញុំឲ្យជា
លោកបានព្យាយាមមើលរោគា ខ្ញុំយូរវេលាពុំជាសោះ ។
តាំងពីថ្ងៃនេះទៅមុខលោក បើរោគខ្ញុំរើឈឺទៀតហ្មោះ
កុំព្រួយអញ្ជើញមកឲ្យសោះ ឲ្យតែលានោះមកបានហើយ » ។

---

ពន្យល់ពាក្យ.— ភាត់— កិ. ភាត់នឹងរំពាត់

ទោមនស្ស — ន. សេចក្ដីតូចចិត្ត — អាក់អន់ចិត្ត ។

ព្យាយាម — ន. ការប្រឹងប្រែង ។

បញ្ចមដ្ឋានទី ១

## នព្វន្ត

*លេខចែកជំនួសអនិយមភាគ សារៀនអំពីលេខទាំង៤យ៉ាង ចំណោទគុណលេខទាំង៤យ៉ាង ជំនួសតក់និងទសភាគ សារៀនហាត់គិតលេខដោយបញ្ញា ចែកជំនួសទីង ០,៥០, និង ០,២៥ ។*

# អាទិត្យទី១— អំពីលេខចែកចំនួនអនិយមភាគ

ឧទាហរណ៍ មនុស្សម្នាក់ស៊ីឈ្នួលធ្វើការ ក្នុង១អាទិត្យ ៣៩ ម៉ោង តើអ្នកនោះធ្វើការក្នុង ១ ថ្ងៃប៉ុន្មានម៉ោង បើអ្នកនោះឈប់ពល់តែថ្ងៃអាទិត្យ ។

របៀបពន្យល់ៈ អ្នកនោះធ្វើការក្នុង ១ អាទិត្យប៉ុន្មានថ្ងៃ ។ ក្នុង៦ថ្ងៃអ្នកនោះធ្វើប៉ុន្មានម៉ោង ។ ចុះបើក្នុង ១ ថ្ងៃវិញ តើអ្នកនោះធ្វើការតិចជាងឬច្រើនជាង៦ថ្ងៃ ។ តិចជាងប៉ុន្មានដង ។

របៀបធ្វើលេខៈ ៣៦ម៉ៈ៦ៈ= ក្នុង ៣៦ មាន ៦ ប្រាំមួយដង

| | |
|---|---|
| ៣៦ម | ៦ |
| ៣ | ៦, ៣០ |
| + ៦០ | |
| ១៨០ម.ន | |

៦ × ៦ = ៣៦ម ។ យកទៅកាត់នឹង ៣៩ សល់ ៣ ម៉ោង ។ នេះចែកនឹង៦មិនបាន ត្រូវបំលែងឲ្យទៅជាមីនុត ១ម៉ = ៦០មន × ៣ = ១៨០ម.ន ក្នុង ១៨០ មីនុតមាន ៦ សាមសិបដង

៦ម.ន × ៣០ = ១៨០ម.ន ។ យកទៅកាត់នឹង ១៨០ គ្មានសល់អ្វីទេ ។ ហើយថា អ្នកនោះធ្វើការក្នុង១ថ្ងៃ ៦ ម៉ោងនិង ៣០ មីនុត ។

បើចង់ពញ្ញាក់ឲ្យឃើញខុសត្រូវ ឲ្យគុណកំណត់ពេលដែលធ្វើការក្នុង១ថ្ងៃ នឹង៦ថ្ងៃ នឹងឃើញកំណត់ពេលដែលធ្វើការក្នុង៦ថ្ងៃគឺ ៣៩ម៉ ។

សេចក្តីរំលឹកៈ កាលណាចំនួនសេស តូចជាងជើងហារនឹងចែកមិនបាន ត្រូវបំលែងចំនួនសេសនេះឲ្យតូចទៅ គឺបំលែងម៉ោងទៅជាមីនុតៗទៅជានាទី (គុណចំនួនសេសនឹង៦០)

បើលេខដំណាំងមានចំនួនមីនុតផង ត្រូវយកចំនួនដែលចំចែកឃើញនោះ ទៅបូករួមទាំងចំនួនមីនុតនោះ ។

ឧបមា: ១៣ម៉ ២៥ | ៥

៣ | ២,៤១

\+ ៦០ម.ន

១៨០ + ២៥

២០៥ ម.ន

០៥

០

ការហាត់បញ្ជាក់: ឲ្យធ្វើឲ្យបានច្រើននៅលើក្តារខៀន ១២ម : ៣ ។ ២១ម,១៤ : ៧ ។ ៣២ម,៤០ : ៧ ។ ៤៨ម,៣៦ម.ន,២៩ន : ១២ ។

ការហាត់សរសេរ: ក្មេងកាពជការម្នាក់ធ្វើការក្នុង១ថ្ងៃ ៥ម,៣០មន លុះធ្វើបាន ២៦ ថ្ងៃ បើកបៀវត្សបាន ៤.០៦៧ រៀល តើអ្នកនោះបានឈ្នួលក្នុង ១ ម៉ោងប៉ុន្មានរៀល ។

## អាទិត្យទី ២– សារៀនអំពីលេខបូកចំនួនទសភាគ

ការគិតលេខដោយបញ្ញា: ឲ្យសិស្សគិតគួរឲ្យបានច្រើនតាមវិធានេះ

៧រ + ៤ = ៦រ,៧ + ០រ,០៩ = ៥ម,៩៣ + ០ម,០៧ = ០គក្រ៨២ + ៣,១៨ =

បំណោទងាយៗគិតមាត់ទទេ: សិស្សម្នាក់ទិញសៀវភៅសរសេរ ១ ថ្ងៃ ៣រ,៥០ ទៅថ្ងៃ១ថ្ងៃ ១រ,៣៧ តើចំណាយអស់ប៉ុន្មាន ។

គេកាត់ខ្សែ១កំណាត់ប្រវែង ៧ម,៣៩ យកមកតភ្ជាប់នឹងមួយកំណាត់ទៀត ប្រវែង ៤ម,៦៣ តើខ្សែដែលគេតរួចប្រវែងប៉ុន្មាន ?

ការហាត់លើក្ដារខៀនៈ *សុំលោកគ្រូគិតរកជំនួនដាក់ឲ្យសិស្សបូកចុះ*

ការហាត់សរសេរៈ *សុំជ្រើសរើសរកបំណោទដាក់ឲ្យធ្វើផងចុះ*

សារៀនលេខបូកជំនួនអនិយមភាគៈ *ឲ្យសិស្សបូកជំនួននេះឲ្យបានច្រើនដោយបញ្ញា និងនៅលើក្ដារខៀន ព្រមទាំងបំណោទងាយៗ*

ការហាត់សរសេរៈ *ក្នុង១ពេលល្ងាច សិស្សម្នាក់រៀនមេទន្ទេញអស់ ០ម,៤៧ម.ន ធ្វើកិច្ចការអស់ ១ម,៣៥ម.ន ហើយមើលសៀវភៅអស់ ២ម,១៥ម.ន តើសិស្សនោះរវល់អស់ប៉ុន្មានម៉ោង ក្នុង១ពេលនោះ ?*

## អាទិត្យទី៣– សារៀនអំពីលេខសងជំនួនទសភាគ

*លេខសងជំនួនអនិយមភាគ*

*សុំមើលរបៀបបង្រៀនលេខបូកជំនួនទសភាគ*

## អាទិត្យទី៤– សារៀនអំពីលេខគុណជំនួនទសភាគនឹងអនិយមភាគ

# រង្វាស់រង្វាល់

## អាទិត្យទី ១– សារៀនអំពីម៉ែត្រ នឹងខ្នាតប្រវែងរបស់ខ្មែរ

*ដូចបានដំរាបមុនមកស្រាប់ហើយ និងបង្រៀនវិជ្ជារង្វាស់រង្វាល់ឲ្យបាន*

ប្រយោជន៍ លោកគ្រូត្រូវតែគិតលៃលក រកឲ្យខានតែបានរង្វាស់រង្វាល់គួរខ្លួនទិញរួចយកទៅគ្រប់យ៉ាង មកឲ្យសិស្សស្គាល់ ហើយចេះប្រើប្រាស់ឲ្យចិត្តយ៉ាងមុតមាំ គឺវាស់ វាល់ ថ្លឹង ទិញដូរជាដើម ។

ទិងបង្រៀនខ្នាតប្រវែង ត្រូវការ ម៉ែត្រឈើបត់ ម៉ែត្របន្ទាត់ ម៉ែត្រសំពត់ ម៉ែត្រដែក ស្ពាន់ កន្លះម៉ែត្រ ពីរម៉ែត្រ ដេស៊ីម៉ែត្រ ឌូប្លដេស៊ីម៉ែត្រ ហត្ថ ខ្នាតហ្វូន ។

របៀបបង្រៀន: ឲ្យហាត់ប្រមាណរួចវាស់បញ្ជាក់ ប្រវែងវត្ថុដែលវែងជាងខ្នាតប្រធាន ដែលខ្លីជាងម៉ែត្រ វត្ថុដែលវែងជាងហត្ថ ដែលខ្លីជាងហត្ថ រួចឲ្យបំបែកជាដេកាម៉ែត្រ ជាហិកតូម៉ែត្រ ជាគីឡូម៉ែត្រ ជាដេស៊ីម៉ែត្រ ជាសង់ទីម៉ែត្រ ជាមីលីម៉ែត្រ រួចឲ្យគិតផ្ទុយពីនោះទៅវិញ ។ ឯរបៀបបង្រៀនខ្នាតខ្មែរក៏ធ្វើដូចគ្នា ។

ការហាត់គិតគូរឲ្យប្រឹកនឹងបញ្ហា ឬនៅលើក្ដារធ្នង: ឲ្យធ្វើឲ្យបានច្រើន ក្ន ១.៣៧៥ ម៉ែត្រ មានប៉ុន្មានគីឡូម៉ែត្រ ។ ប៉ុន្មានហិកតូម៉ែត្រ ។ ប៉ុន្មានដេកាម៉ែត្រ ។ ៣៦៩ ដេស៊ីម៉ែត្រ មានប៉ុន្មានម៉ែត្រ ។ ប៉ុន្មានសង់ទីម៉ែត្រ ។ ល ។

១៨ ម៉ែត្រត្រូវជាប៉ុន្មានហត្ថ ។ ៧៤ ហត្ថមានប៉ុន្មានម៉ែត្រ ។ ១ ហត្ថ ១/២ មានប៉ុន្មានចំអាម ។ ២៤ ចំអាមត្រូវជាប៉ុន្មានហត្ថ ។ ល ។

ការហាត់សរសេរ– សុំលោកគ្រូជ្រើសរើសកិច្ចការដាក់ឲ្យសិស្សធ្វើផ្ចិតចុះ ។

## អាទិត្យទី ២– សារៀនអំពីលីត្រ

របស់ដែលត្រូវយកមកបង្រៀន: លីត្រគ្រប់យ៉ាង ឈើ ដែក ស្ពាន់ រង្វាល់ដែលធំជាងរង្វាល់ប្រដាន រង្វាល់ដែលតូចជាងលីត្រ ផ្ទាំងគំនូរមានរូបរង្វាល់គ្រប់យ៉ាង ថាំង តៅ កណ្ដាំង ទឹកមួយក្អម អង្ករមួយពុំទូក ប៉ោតទទេ ។

របៀបបង្រៀន: សុំធ្វើដូចកាលបង្រៀនខ្នាតប្រវែង គឺឲ្យសិស្សប្រមាណចំណុះវត្ថុផ្សេងៗ ដូចជាក្អម ប៉ោត ល្អី ។ល។ ហើយឲ្យវាល់បញ្ជាក់មើល រួចឲ្យបំប្លែងទៅជារង្វាល់ដែលធំជាងលីត្រដែលតូចជាងលីត្រ ឲ្យគិតទៅជាតៅ ជាថាំង ជាកណ្ដាំង រួចឲ្យគិតផ្ទុយអំពីនោះវិញ ។

ការហាត់គិតឧប្បិក: សុំឲ្យធ្វើដូចកាលបង្រៀនខ្នាតប្រវែង ។

ការហាត់សរសេរ: សុំជ្រើសរើសកិច្ចការដាក់ឲ្យធ្វើផ្ចិតចុះ ។

## អាទិត្យទី ៣– សារៀនអំពីក្រាមនិងកូនទម្ងន់

របស់ដែលត្រូវយកមកបង្រៀន: ជញ្ជីងដែលមានថាសស្ពាន់ពីរ ជញ្ជីងមាសដែលមានថាសព្យួរ ជញ្ជីងត្រាជូរបស់ទ្រ កូនទម្ងន់បន្ទះដែល

ស្រោលជាន់ក្រោម កូនខ្ទង់ស្ពាន់ កូនខ្ទង់ដែក ៦ ជ្រុង និង ៤ ជ្រុង ។

របៀបបង្រៀនៈ សុំធ្វើដូចមុនៗ ឲ្យប្រមាណខ្ទង់ត្រូវនឹងថ្លឹងបញ្ជាក់ រួចសឹមបំបែកទៅជាខ្ទង់ធ្ងន់ជាងខ្ទង់ប្រពាម ស្រោលជាន់ក្រោម ទើបគិតតាមខ្ទង់ខ្មែរ ។

ការហាត់គិតឱ្យប្រឹកៈ សុំជ្រើសរើសឲ្យធ្វើជនចុះ ។

## អាទិត្យទី ៤– សារៀនអំពីបិយវត្ត

របស់ដែលត្រូវយកមកបង្រៀនៈ សាច់ប្រាក់ ១ រៀល ក្រដាស ប្រាក់ ១ រៀល (គ្រប់យ៉ាងជាន់ចាស់និងថ្មី) ក្រដាស ៥ រៀល (ចាស់និងថ្មី) ក្រដាស ២០ រៀល (ចាស់និងថ្មី) ក្រដាស ៥០ រៀល ក្រដាស ១០០ រៀល (ចាស់និងថ្មី) ប្រាក់ ០,៥០ ០,២០ ០,១០ ក្រដាស ០,៥០ ០,២០ ០,១០ លុយ ៥ សេន ២ សេន ១ សេន ។ ផ្ទាំងគំនូរមានរូបបិយវត្តបារាំងសេស ។

របៀបបង្រៀនៈ ឲ្យសិស្សហាត់ផ្គូររូបិយវត្តពីធំទៅតូច ពីតូចទៅធំ រួចឲ្យផ្គូររូបិយវត្តណាដែលនៅជារូបិយវត្តបារាំងហើយផ្ទុយពីនោះ ឲ្យទិញដូរវត្ថុផ្សេងៗហើយបែបចាយរូបិយវត្ត ។

**ធរណីមាណសាស្ត្រ**

## អាទិត្យទី ១ .– សារៀនអំពីផ្ទៃ ៤ ជ្រុងស្មើ

របៀបបង្រៀន.— ចោទសួរអំពីទំហំនៃផ្ទៃ ៤ ជ្រុងស្មើ ។ ទឹងគេ ផ្ទៃកន ៤ ជ្រុងស្មើ ត្រូវធ្វើដូចម្ដេចខ្លះ ។ ទឹងគិតគេពាក់កណ្ដាលបរិវេណ ។ ទឹងគេបរិវេណទាំងមូល ។

ការហាត់គិតគូរដោយបញ្ញា ឬនៅលើក្ដារខៀន: សុំឱ្យធ្វើឱ្យបានច្រើន ស្រែមួយកន ៤ ជ្រុងស្មើ ១ ជ្រុងប្រវែង ៧ ម៉ែត្រ គេពាក់កណ្ដាលបរិវេណ ស្រែនោះទំហំប៉ុន្មាន ។ បរិវេណទាំងមូលទំហំប៉ុន្មាន ។ ស្រែនោះទំហំប៉ុន្មានម៉ែត្រក្រឡា ។

អ្នកចំការម្នាក់ទិញដី ១ ក្បាលកន ៤ ជ្រុងស្មើ ១ ជ្រុងប្រវែង ៣៦ ម៉ែត្រ ថ្លៃក្នុង ១ ម៉ែត្រក្រឡា ៨៧៛,៥០ តើអ្នកនោះចំណាយអស់ប៉ុន្មាន ។

ការហាត់សរសេរ.— គេទិញដីកន ៤ ជ្រុងស្មើ ១ កន្លែង ១ ជ្រុងប្រវែង ៥៨ ម៉ែត្រ ៥០ ថ្លៃក្នុង ១ ម៉ែត្រក្រឡា ៥៩៛,៣៥ ហើយគេធ្វើរបងព័ទ្ធជុំវិញ គិតៈ៧ក្នុង ១ ម៉ែត្រអស់ ២៣៛,២៥ តើអ្នកចំណាយទាំងអស់អស់ប៉ុន្មាន ។

## អាទិត្យទី ២.— សារៀនអំពីផ្ទៃ ៤ ជ្រុងទ្រវែង

របៀបបង្រៀន.— ធ្វើដូចគាលបង្រៀនផ្ទៃ ៤ ជ្រុងស្មើ. ចោទសួរឱ្យគេទ័យ ពាក់កណ្ដាលបរិវេណ បរិវេណទាំងមូល ផ្ទៃក្រឡា ។

កា.ប.ហា គេដឹងបរិវេណហើយទឹងបណ្ដោយ គេធ្វើដូចម្ដេចទឹងឱ្យឃើញទទឹង ។ គេដឹងបរិវេណនិងទទឹង ត្រូវធ្វើដូចម្ដេចឱ្យឃើញបណ្ដោយ ។

បើមិនឲ្យឃើញបណ្ដោយ ហើយដឹងផ្ទៃនឹងទទឹង គេត្រូវធ្វើដូចម្ដេច ។ ធ្វើដូចម្ដេចឲ្យឃើញទទឹង គេដឹងផ្ទៃនឹងបណ្ដោយ ។ល។

ការហាត់ដោយបញ្ញានឹងនៅលើក្ដារខៀន : សុំជ្រើសរើសកិច្ចការឲ្យហាត់គិតគួរដូចរបៀបបង្រៀនផ្ទៃ ៤ ជ្រុងស្មើ ។

ការហាត់សរសេរ : សុំលោកគ្រូលៃលកជ្រើសរើសកិច្ចការដាក់ឲ្យធ្វើផ្សំចុះ ។

## អាទិត្យទី ៣ .— សារៀនអំពីត្រីកោណ

របៀបបង្រៀន .— ចោទសួរដូចកាលបង្រៀនផ្ទៃ ៤ ជ្រុងស្មើ ផ្ទៃ ៤ ជ្រុងទ្រវែង ឲ្យរកន័យ រកបរិវេណ ។

ត្រីកោណមានប៉ុន្មានយ៉ាង ។ អ្វីខ្លះ ។ និងរកបរិវេណត្រីកោណស្មើជ្រុងតែ ២ ធ្វើដូចម្ដេចខ្លះ ។ ត្រីកោណស្មើជ្រុង ។ ត្រីកោណឥតស្មើជ្រុង ។ ត្រីកោណស្មើជ្រុងទាំង ៣ ។ ធ្វើដូចម្ដេចនឹងរកក្រឡាផ្ទៃត្រីកោណ និងរកបាត ។ និងរកកំពស់ ។

កាហាត់គិតគួរដោយបញ្ញា ឬ លើក្ដារខៀន : សុំធ្វើដូចមុន ។

ការហាត់សរសេរ : សុំលោកគ្រូលៃលកជ្រើសរើសរកកិច្ចការដាក់ឲ្យធ្វើផ្សំចុះ ។

## អាទិត្យទី ៤.– សារៀនអំពីវណ្ណមណ្ឌល់និងផ្ទៃរង្វង់

របៀបបង្រៀន : *សុំសាកសួររំឭកពីកាលជាន់មុន ៗ ឲ្យគេន័យខ្នាតវណ្ណមណ្ឌល់ (បន្ទាត់ពុះទីផ្ចិត) របៀបគេប្រើវណ្ណមណ្ឌល់គេបន្ទាត់ពុះ រកកាំ ៗ គេន័យផ្ទៃរង្វង់ យ៉ាងគិតគូរផ្ទៃរង្វង់ រកកាំ ៗ*

បរិច្ចណាដ្ឋាន

**នព្វន្ត**

*តាមកំណត់បែបវិជ្ជាកន្លែងនេះជាខែបុណ្ណាំសិក្សា ត្រូវសារបង្រៀនអំពីវិជ្ជាដែលបានបង្រៀនតាំងពីដើមឆ្នាំមក ហេតុនេះសូមលោកគ្រូ ដែលមើលវិជ្ជាត្រង់ណាដែលលោកគ្រូប្រាថ ថាសិស្សពុំទាន់យល់ច្បាស់ ឬ ពុំទាន់ចេះច្បាស់នោះយកមកបង្រៀនបញ្ជាក់ឲ្យសិស្សបានយល់បានចេះច្បាស់ឡើង ៗ*

*១វិញទៀត កូនសិស្សថ្នាក់នេះត្រូវឡើងទៅថ្នាក់សាចិកដ្ឋាន ត្រូវចេះធ្វើចំណោទ ហេតុនេះសូមបង្វឹកសិស្សឲ្យចេះធ្វើចំណោទឲ្យស្ទាត់ ៗ*

*ឯចំណោទនោះតាមតែលោកគ្រូតែងឲ្យសមល្មមនឹងវិជ្ជារបស់សិស្សនៅថ្នាក់លោកគ្រូ ៗ*

*សូមជូនរបៀបតទ្យល់ចំណោទជាគំរូខាងក្រោមនេះ ៗ*

*លោកគ្រូសរសេរចំណោទទុកនៅលើក្ដារខៀន ៗ*

**បំណោទ** — ម្ដាយខ្ញុំមានប្រាក់ ៩៣ រៀល គាត់ទិញសំពត់ ៣ ម៉ែត្រអស់ ៤៧ រៀលទិញអង្ករអស់ ២៥ រៀល ។ តើគាត់ត្រូវនៅសល់ប្រាក់ប៉ុន្មានរៀលទៀត ។

របៀបបង្រៀន —

១ — ឲ្យសិស្សមើលសេចក្ដីបំណោទ -( ២ ឬ ៣ នាក់ )

២ — សួរសាកពន្យល់ឲ្យសិស្សយល់សេចក្ដីបំណោទនោះ

៣ — សួរសាករបៀបធ្វើបំណោទនោះ

៤ — ឲ្យសិស្សធ្វើបំណោទនោះលើក្ដារខៀន ។

ការហាត់បញ្ជាក់ .— តែងបំណោទបែបខាងលើនេះឲ្យសិស្សធ្វើនៅលើក្ដារខៀនល្បងមើល ។

ការហាត់បញ្ជាក់នៅក្នុងសៀវភៅ .— សូមតែងជាបំណោទបែបខាងលើនេះឲ្យសិស្សធ្វើនៅក្នុងសៀវភៅ ។

## រង្វាស់ - រង្វាល់

ដូចជាក្បួនពន្ធដែរ រង្វាស់ - រង្វាល់ត្រូវសាបង្រៀនឡើងវិញអំពីវិជ្ជាដែលបានបង្រៀនរួចហើយ ។

របៀបសាបង្រៀនវិជ្ជានេះត្រូវនាំសិស្សហាត់វាស់ - វាល់ - ថ្លឹង ឲ្យចេះស្ទាត់ផង ត្រូវឲ្យបំបែកទៅជារង្វាស់ - រង្វាល់ទម្ងន់ធំជាង ឬ តូចជាងប្រធានឲ្យស្ទាត់ ហើយតែងជាបំណោទឲ្យសិស្សធ្វើផង ។

កុមារដ្ឋាន

## នព្វន្ត

សារៀន មេរៀនផ្សេងៗដែលបានរៀនតាំងពីដើមឆ្នាំ - ចំណោទផ្សេងៗ និងវិធីហាត់ធ្វើលេខ ។

## រង្វាស់ – រង្វាល់

សាបង្រៀនអំពីមេរៀនផ្សេងៗ ដែលបានបង្រៀនតាំងពីដើមឆ្នាំ - សូមនាំសិស្សគិតលេខនិងចំណោទផ្សេងៗឲ្យបានច្រើន ។

IMPRIMERIE
A. PORTAIL
PHNOM-PENH

TIRAGE 2.706 EX.